# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាប្រសិទ្ធិពរលើប្រេងនៅភ្នំពេញថ្មី
# ថ្ងៃទី០៥ មេសា ២០១៧

អត្ថបទទី១៖ ដន ៣,១៤-២០.៩១-៩២.៩៥
អត្ថបទទី២៖ បច ដន ៣,៥២-៥៦
ដំណឹងល្អ៖ យហ ៨,៣១-៤២

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះដែលយើងប្រសិទ្ធិពរលើប្រេងគ្រីស្មាស ជាឱកាសមួយដើម្បីចែករំលែករបៀបពិសេសសម្រាប់បូជាចារ្យ។ ប៉ុន្មានថ្ងៃទៀតយើងចូលនៅក្នុងអាទិត្យពិសិដ្ឋ ដែលជាពិធីបុណ្យយ៉ាងអស្ចារ្យសម្រាប់ជីវិតយើងជាបូជាចារ្យ គឺយើងឥតមានព្រះពរទេចាំដល់យប់បុណ្យចម្លងយើងទទួលព្រះពរពីព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ។ ថ្ងៃនេះយើងសុំព្រះជាម្ចាស់ប្រទានពរលើប្រេងសម្រាប់អ្នកជំងឺ លើប្រេងសម្រាប់អ្នកទទួលអប់រំជំនឿ និងលើប្រេងសម្រាប់អគ្គសញ្ញានានា។ ថ្ងៃនេះជាឱកាសមួយ ដើម្បីនឹកឃើញវត្តមានរបស់ព្រះជាម្ចាស់ដែលកំពុងមានប្រសិទ្ធិភាពនៅក្នុងជីវិតយើង។ ពេលក្រុមលោកអភិបាលឡាវ-កម្ពុជាបានជួបសម្តេចប៉ាបជាផ្លូវការកន្លងមក ខ្ញុំបាននិយាយអំពីអ្វីដែលណែនាំឲ្យព្រះសហគមន៍របស់យើងមានជីវិត។

ទីមួយ អ្វីដែលផ្តល់កម្លាំងឲ្យយើងគឺប្រកាសដំណឹងល្អ ដើម្បីឲ្យគ្រីស្តបរិស័ទស្គាល់ព្រះយេស៊ូថែមទៀត យើងមានរបៀបផ្សេងៗដើម្បីចែករំលែកអំណរសប្បាយនៃដំណឹងល្អដល់បងប្អូនឯទៀតៗ។

ទីពីរ យើងធ្វើដូចម្តេចដើម្បីបង្កើតផ្លូងតែមួយនៅក្នុងព្រះសហគមន៍ នៅក្នុងប្រទេសកម្ពុជាយើងមានលោកបូជាចារ្យ បងប្រុសបងស្រី អ្នកស្ម័គ្រចិត្ត មកពីប្រទេសផ្សេងៗជាង៣០ប្រទេស តួនាទីរបស់យើងធ្វើដូចម្តេចដើម្បីឲ្យយើងទៅជាអង្គតែមួយជាមួយព្រះគ្រីស្ត។ ថ្ងៃនេះយើងមានរូបភាពរបស់ព្រះយេស៊ូ ដែលមានបូជាចារ្យទាំងអស់អង្គុយជិតៗគ្នានៅក្នុងបេះដូងរបស់ព្រះយេស៊ូ។

ទីបី យើងធ្វើដូចម្តេចដើម្បីបង្កើតការសន្ទនា រវាងសាសនានឹងសាសនា រវាងព្រះសហគមន៍នឹងវប្បធម៌របស់ប្រទេសកម្ពុជា រវាងមនុស្សនឹងមនុស្ស។ យើងបង្កើតទំនាក់ទំនងផ្ទាល់ ដើម្បីឲ្យមនុស្សអាចមានឱកាសនិយាយគ្នា សម្រុះសម្រួលគ្នា ព្រះរាជ្យរបស់

ព្រះជាម្ចាស់គឺសម្រុះសម្រួលមនុស្សលោកនឹងព្រះជាម្ចាស់ មនុស្សលោកនឹងមនុស្សលោក។

ទីបួន គឺអប់រំចិត្តគំនិត ជាពិសេសសង្គមរបស់យើងដែលបានចូលនៅក្នុងទីផ្សារអាស៊ាន កុំឲ្យយើងគិតតែពីសេដ្ឋកិច្ច កុំឲ្យយើងគិតអំពីផ្សាររកស៊ី ប៉ុន្តែនេះជាតួនាទីរបស់ព្រះសហាគមន៍។ យើងជឿថា ព្រះសហាគមន៍កាតូលិកអាចធ្វើជាអ្នកដឹកនាំ ដើម្បីអប់រំចិត្តគំនិត ដើម្បីអប់រំផ្លូវវិញ្ញាណក្នុងប្រទេសទាំង១០ក្នុងតំបន់អាស៊ីអាគ្នេយ៍។ បន្ថិចទៀត យើងមានតំណាងយុវជនយុវនារីយើង ទៅចូលរួមទិវាយុវជនអាស៊ីនៅឥណ្ឌូនេស៊ី និងនិស្សិតនៃសាលាអប់រំជំនឿសន្តយ៉ូស្វីនទៅម៉ាឡេស៊ី ជាឱកាសមួយដើម្បីអប់រំចិត្តគំនិត និងមានបទពិសោធដោយស្គាល់បងប្អូនឯទៀតៗនៅក្នុងតំបន់របស់យើង។

តួនាទីមួយទៀត យើងជាវត្តមានដ៏ស្ងៀមស្ងាត់ដើម្បីចែករំលែកព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ ដល់មនុស្សដែលគ្មានទីពឹង។ សម្ដេចប៉ាប ចូលចិត្តឲ្យយើងទៅកន្លែងដែលដាច់ស្រយាលនៃផែនដី គឺកន្លែងដែលយើងនៅជាមួយអ្នកក្រីក្រ ជាមួយអ្នកដែលគ្មានទីពឹង ជាមួយអ្នកជំងឺ។ កន្លែងដែលយើងនៅសព្វថ្ងៃ ដោយរបៀបស្ងៀមស្ងាត់ឲ្យយើងចូលយ៉ាងជ្រៅនៅក្នុងជីវិតរបស់មនុស្ស ដើម្បីឆ្លើយតបដល់សេចក្ដីសង្ឃឹមនិងសេចក្ដីត្រូវការរបស់គេ។ នេះជាបេសកកម្មដែលយើងជាគ្រូគង្វាលបានទទួល ដោយដឹងថាព្រះជាម្ចាស់បានជ្រើសរើសយើង ព្រះជាម្ចាស់បានអប់រំយើង និងព្រះជាម្ចាស់បានចាត់ឲ្យយើងទៅ ដើម្បីធ្វើជាគ្រូដ៏សប្បុរសដែលមានបេះដូង ដូចព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ ដើម្បីបម្រើបងប្អូនរបស់យើងនៅប្រទេសកម្ពុជា។

ពិធីបុណ្យអភិបូជា ជាជីវិតរបស់យើងតែម្ដងដែលយើងថ្វាយទៅព្រះជាម្ចាស់ នៅក្នុងសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះគ្រីស្ត។ យើងដឹងហើយ ក្នុងសង្គម និងក្នុងព្រះសហាគមន៍របស់យើងយើងមានតួនាទីច្រើន ពេលខ្លះយើងមានទុក្ខលំបាកយើងមានបញ្ហានៅក្នុងជីវិតរបស់យើងណែនាំឲ្យយើងជឿចិត្ត។ តែបើយើងមិនចេះជឿចិត្ត ប្រហែលយើងលែងមើលបងប្អូនរបស់យើងដូចអ្នកមានដែលមើលមិនឃើញលោកឡាសា។ ការជឿចិត្តរបស់យើងជាសញ្ញាសម្គាល់ដែលព្រះជាម្ចាស់កំពុងធ្វើការនៅក្នុងដួងចិត្តរបស់យើង ដើម្បីយំសើចជាមួយបងប្អូន។ ជួនកាលយើងដូចម៉ាថា ដែលរវល់ច្រើន ប៉ុន្តែជួនកាលយើងត្រូវការអង្គុយ

ដូចព្រះយេស៊ូអង្គុយនៅអណ្តូងទឹក ដែលស្ត្រីសាម៉ារីបានទៅដងទឹកនឹងបានជួបជាមួយព្រះយេស៊ូដែលជាជីវិតអស់កាលជានិច្ច។

ព្រះសហាគមន៍រស់នៅដោយសារអគ្គសញ្ញាព្រះកាយព្រះគ្រីស្ត យើងបានទទួលអភិសេកដើម្បីឲ្យនំប៉័ងនិងស្រាទៅជាព្រះកាយនិងព្រះលោហិតរបស់ព្រះគ្រីស្ត។ ពិតមែនពិធីបុណ្យអភិបូជា អគ្គសញ្ញាព្រះកាយព្រះគ្រីស្ត គឺជាកំពូលនិងជាប្រភពនៃជីវិតរបស់យើង។ ក្នុងពិធីបុណ្យម្តងៗ យើងបង្ហាញអំពីអាថ៌កំបាំងនៃសក្ការៈបូជារបស់ព្រះជាម្ចាស់ គឺព្រះយេស៊ូគ្រីស្តដែលបូជាជីវិត។ ពេលថ្វាយអភិបូជា យើងជាបូជាចារ្យដែលបានទទួលអភិសេក នៅពេលយើងនៅតុអាសនៈ គឺយើងនៅលើតុសក្ការៈបូជារបស់ព្រះគ្រីស្តផ្ទាល់។ ពេលយើងនិយាយ ពេលយើងធ្វើកាយវិការ គឺដើម្បីបង្ហាញពិធីបុណ្យដ៏សក្ការៈរបស់ព្រះសហាគមន៍ ដែលទទួលប្រភពទាំងអស់នៅក្នុងព្រះបន្ទូលរបស់ព្រះគ្រីស្តផ្ទាល់។ ពិតមែនពិធីបុណ្យអភិបូជា សក្ការៈបូជារបស់ព្រះគ្រីស្ត ជាពេលវេលាដើម្បីជួបជាមួយព្រះយេស៊ូផ្ទាល់ និងដើម្បីថ្វាយបង្គំដល់ព្រះជាម្ចាស់ដែលជាព្រះបិតារបស់យើង។ យើងជាបូជាចារ្យយើងបានទទួលតួនាទីការពារថែរក្សាអាថ៌កំបាំងដ៏អស្ចារ្យនេះ និងយើងទទួលមរតកដ៏អស្ចារ្យនៃព្រះសហាគមន៍។ តាមរយៈដៃរបស់យើង ដែលជាដៃរបស់អ្នកបាបព្រះជាម្ចាស់បានជ្រើសរើសយើង ដើម្បីឲ្យព្រះយេស៊ូគ្រីស្តមានវត្តមានសម្រាប់មនុស្សទាំងអស់ តាមរយៈអភិបូជាដែលយើងថ្វាយជារៀងរាល់ថ្ងៃ។ ដើម្បីឲ្យព្រះជាម្ចាស់ទទួលការថ្វាយបង្គំ ពីមនុស្សទាំងអស់តាមរយៈអភិបូជាដែលយើងថ្វាយពីមួយថ្ងៃទៅមួយថ្ងៃ។

នេះជាឱកាសមួយ សម្រាប់បូជាចារ្យអំពីរបៀបដែលយើងថ្វាយអភិបូជាដែលជាអាថ៌កំបាំងដ៏ខ្ពង់ខ្ពស់បំផុតនៃជំនឿរបស់យើង ដើម្បីឲ្យយើងថ្វាយអស់ពីដួងចិត្ត និងដើម្បីណែនាំឲ្យព្រះគ្រីស្តមានវត្តមាន។ ផ្លែងសក្ការៈ បទចម្រៀង សំដី កាយវិការ ភាពស្ងៀមស្ងាត់ ព្រះវិហារ អាវសម្រាប់សូត្រធម៌ សម្ភារៈសក្ការៈបូជា អ្វីៗទាំងអស់ដែលយើងមានដល់ពេលវេលាដើម្បីយកពេលអង្គុយរិះគិតជាមួយគ្នា នៅក្នុងសេចក្តីសុខសាន្តដើម្បីរៀបចំពិធីបុណ្យរបស់យើងយ៉ាងច្បាស់លាស់ ដើម្បីបម្រើព្រះជាម្ចាស់ ដើម្បីបម្រើបងប្អូនរបស់យើង ដើម្បីបម្រើពិភពលោក។ ដោយសារអភិបូជានីមួយៗ ជាអភិបូជាដែលណែនាំឲ្យយើងបើកចិត្តគំនិតដល់ពិភពលោកទាំងមូល ជាអភិបូជាដែលប្រមូលមនុស្សទាំងអស់ដើម្បីឲ្យព្រះយេស៊ូគ្រីស្តទទួលការលើកតម្កើងនៅលើអាសនៈ ដោយសារជាព្រះយេស៊ូគ្រី

ស្តដែលប្រទានព្រះកាយនិងព្រះលោហិតឲ្យយើង។ សម្តេចប៉ាប បេណេឌីក្ទទី១៦ ធ្លាប់និយាយថា នៅពេលពិភពលោកទាំងមូលរួមគ្នាទៅជាពិធីបុណ្យរបស់ព្រះជាម្ចាស់ នៅពេលពិភពលោកទាំងមូលថ្វាយបង្គំដល់ព្រះជាម្ចាស់ នៅពេលនោះពិភពលោកនឹងទទួលការសង្គ្រោះ។ ខ្ញុំសូមជូនពរ ដើម្បីឲ្យអាទិត្យពិសិដ្ឋនេះទៅជាអាទិត្យមួយដែលជួយយើងឲ្យយើងចូលនៅក្នុងអាថ៌កំបាំងដ៏អស្ចារ្យនៃជីវិតរបស់យើងជាបូជាចារ្យ គឺជាបូជាចារ្យដែលលះបង់ចោល ជាបូជាចារ្យដែលបានបូជាជីវិត ដូចព្រះយេស៊ូ ដើម្បីបម្រើ ដើម្បីស្រឡាញ់ ដើម្បីកោតសរសើរព្រះជាម្ចាស់ ដើម្បីឲ្យមនុស្សលោកទទួលការសង្គ្រោះ។ យើងជាបូជាចារ្យ ជាអ្នកដែលបូជាជីវិតដើម្បីឲ្យមនុស្សលោកមានជីវិត **“ឱព្រះយេស៊ូអើយ ជាគ្រូគង្វាលដ៏សប្បុរស ជាព្រះកាយដ៏ពិតប្រាកដ សូមអាណិតអាសូរដល់យើង សូមប្រទានម្ហូបអាហារឲ្យយើង សូមថែរក្សាយើងជានិច្ច សូមជួយយើងឲ្យយើងមើលឃើញអំពើល្អប្រសើរបំផុតនៅលើផែនដីនេះ ឱព្រះយេស៊ូគ្រីស្តអើយ ដែលដឹងអ្វីៗទាំងអស់ ដែលអាចធ្វើអ្វីៗទាំងអស់ ដែលមានឥទ្ធានុភាពសព្វប្រការ ដែលជាម្ហូបអាហារនៅលើផែនដីនេះ សូមទទួលស្វាគមន៍យើងនៅស្ថានលើ ដើម្បីឲ្យយើងធ្វើជាភ្ញៀវកិត្តិយស ដោយទទួលមរតកដ៏អស្ចារ្យនៅក្នុងក្រុមគ្រួសារនៃសន្តសន្តិបុគ្គលទាំងឡាយ”**។ អាម៉ែន។